សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ : ២៣១

ចុះថ្ងៃទី : ១៦-០៥-០៨

សាលដីកា

លេខ : ០៨ "ខ"

ចុះថ្ងៃទី : ២៥-០១-១០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២៥ ខែមករា ឆ្នាំ២០១០ ដោយមានសមាសភាពដូចខាងក្រោម

**ក្រុមប្រឹក្សាជំនុំជម្រះ**

**លោក** [redacted] **ជាប្រធាន**

**លោក** [redacted] **ជាចៅក្រមប្រឹក្សា**

**លោក** [redacted] **ជាចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក** [redacted]

**ក្រឡាបញ្ជី**

**កញ្ញា** [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ២៣១ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨ រវាង

- ជនជាប់ចោទឈ្មោះ [redacted] **សារ៉ាក់** ហៅ **ខ្មៅ** ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ កើតនៅ [redacted] ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (រ) មានកូន ០៦នាក់ ទោសពីមុន ធ្លាប់ជាប់គុក នៅខេត្តតាកែវ ១១ខែ ពីបទ ប្លន់។ ចាប់ខ្លួនថ្ងៃ ១៧ ខែ ធ្នូ ឆ្នាំ ២០០៧ ឃុំខ្លួនថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ បច្ចុប្បន្ននៅក្នុងឃុំ ម១ ក្រសួងមហាផ្ទៃ។

- <u>ត្រូវជាប់ចោទពីបទ</u> : " **ប្លន់** " ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោស តាមមាត្រា ០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ និស្សិតន័រតុន ទីលំនៅសព្វថ្ងៃ [redacted]

- តាមបណ្តឹងឧទ្ធរណ៍លេខ ៥៥៨ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាក់ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៧ "ឋ" ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចទាំងមូល។

### <u>ដំណើររឿងតាមបណ្តឹង</u>

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ របស់ [redacted] ចន្ថា និង ចម្លើយនៅសវនាការ ថាកាលពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥ ប្រហែលម៉ោង ១០យប់ ខ្លួន និងមិត្តភក្តិឈ្មោះ បូរី ជិះម៉ូតូ C100 ក្ងរ៉េ ពណ៌ប្រហ្ម លេខតួ១៣៤២៧៨១ ,

លេខម៉ាស៊ីន ១៣៤២៧៨៦ គ្មានផ្លាកលេខ ពីស្រុកគងពិសី ខេត្តកំពង់ស្ពឺ តាមផ្លូវជាតិលេខ ៣ ដល់ចំណុចវត្តស្លែង ចំណុ
វិទ្យាស្ថានស្រាវជ្រាវ កសិកម្មរុក្ខជាតិ ក្នុងភូមិស្រែញ៉រ សង្កាត់ពងទឹក ជួបចោរមួយក្រុមមានគ្នា ០៧ទៅ១០នាក់ ប្រដាប់ដោ
កាំភ្លើង AK ១ដើម ស្លៀកពាក់ស៊ីវិល ខ្លះស្លៀកក្រមាំ ប្លន់យកម៉ូតូខ្លួន ខ្លួនក៏ដួលទៅដី ពួកវាក៏អូសខ្លួន និង គិន 
ទៅខាងកើតថ្នល់ ពួកវាសួរថាខ្លួនមានលុយឬ ខ្លួនថាមាន ១៥ដុល្លារ មិត្តភក្តិខ្លួនមាន ១០ដុល្លារ ពួកវាយកទាំងអស
យកម៉ូតូ១គ្រឿង, យកអត្តសញ្ញាណប័ណ្ណប្រជាជន ១សន្លឹក, ប័ណ្ណបោះឆ្នោត ១, កាតក្រុមហ៊ុន, ឯកសារក្រុមហ៊ុន និ
មួកការពារ។ ភិនភាគមាឌតូចល្មម កំពស់ ១,៧៥ ទៅ ៦០ម៉ែត្រ។ ប្លន់បានពួកវាជិះម៉ូតូខ្លួនទៅបាត់ ខ្លះដើរកាត់វាលស្រែ
បន្ទាប់មកខ្លួនប្តឹងប៉ូលីស។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ២៧ "ប" ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេ
ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ

១. ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]វិត ហៅ [redacted]ដាន ភេទប្រុស អាយុ ៤២ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេ
០៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតចាប់ពីថ្ងៃអនុវត្តចប់នៃទោសដែលមានក្នុងសាលក្រមមុនៗ។ ពីបទ " ប្លន់ " ប្រព្រឹត្តនៅ ក្រុងភ្នំពេ
កាលពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥ តាមបញ្ញត្តិមាត្រា ០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២. ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សារ៉ាក់ ភេទប្រុស អាយុ ៣១ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៧ឆ្ន
(ប្រាំពីរឆ្នាំ) គិតចាប់ពីថ្ងៃចាប់ខ្លួនបាន ពីបទ " ប្លន់ " ប្រព្រឹត្តនៅ ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០
តាមបញ្ញត្តិមាត្រា ០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៣. ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ផល ភេទប្រុស អាយុ ៤៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៧ឆ្ន
(ប្រាំពីរឆ្នាំ) គិតចាប់ពីថ្ងៃចាប់ខ្លួនបាន ពីបទ " ប្លន់ " ប្រព្រឹត្តនៅ ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០
តាមបញ្ញត្តិមាត្រា ០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៤. សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ ចិន វិត កំបាំងមុខជនជាប់ចោទ
[redacted] សារ៉ាក់ និង [redacted] ផល ចំពោះមុខមេធាវីជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិអោយប្តឹងទាស
និងឧទ្ធរណ៍ តាមកំណត់ច្បាប់។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៥៥៨ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted]សារ៉ាក់
សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៧ "ប" ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ
គ្រប់ចំណុចទាំងមូល។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍

- បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍

**តាមពេលសវនាការ**

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុជូនអង្គសវនាការ

ប្រធានក្រុមប្រឹក្សាអោយក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយនៅ
សាលាដំបូងរាជធានីភ្នំពេញ។ ៦

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

១. តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] រិត បានអះអាងថា ខ្លួន និង បក្សពួកមានឈ្មោះ [redacted] ផល [redacted] សារ៉ាក់ និង អាសឿន ពិតជាបានធ្វើសកម្មភាពប្លន់ម៉ូតូមែន។

២. សាលក្រមព្រហ្មទណ្ឌលេខ ២៧ "ឋ" ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ សំរេចមានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវី

សុំបដិសេធសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ សុំចៅក្រមលើកលែងការចោទប្រកាន់លើកូនក្ដីរបស់ខ្លួន។

- ក្រោយពីបានស្ដាប់អំនានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំនានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា

១. បណ្ដឹងឧទ្ធរណ៍លេខ ៥៥៨ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] សារ៉ាក់ ហៅ ខ្មៅ ធ្វើឡើងនៅក្នុងកំណត់ច្បាប់

២. ជនជាប់ចោទ ថាកាលពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥ ខ្លួនពុំបានមកភ្នំពេញ ធ្វើសកម្មភាពប្លន់ជនរងគ្រោះទេ គឺនៅក្នុងខែ កញ្ញា ឆ្នាំ ២០០៥ ខ្លួននៅឯស្រុកជាមួយប្រពន្ធជួយដកស្ទូង។ ខ្លួនស្គាល់ [redacted] រិត, ជឹម ផល និងឆន នៅភូមិជាមួយគ្នា

២.១ តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] រិត ថាកាលពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥ បក្សពួកខ្លួនមាន : ១. [redacted] ២. [redacted] ផល ៣. [redacted] សារ៉ាក់ ហៅ ខ្មៅ ៤. អាភឿន និងខ្លួន ពិតជាបានធ្វើសកម្មភាពប្លន់យកម៉ូតូជនរងគ្រោះប្រាកដមែន ដោយពេលនោះ ០៣នាក់ចាំស្ទាក់ម៉ូតូ ឯខ្លួនឈរចាំលើកម៉ូតូជិះពេលម៉ូតូដួល, ក្រោយពេលប្លន់ [redacted] ផល អោយលុយខ្លួន ៥ ០០០រៀល។

៣. មានពិរុទ្ធលើជនជាប់ចោទ ពីបទប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥ តាមមាត្រា ០៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៤. សាលក្រមព្រហ្មទណ្ឌលេខ ២៧ " ឋ " ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១. ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៥៥៨ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ របស់ឈ្មោះ [redacted] សារ៉ាក់ ហៅ ខ្មៅ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមលេខ ២៧ "ឋ" ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។/.

៣. បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ

សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហអនុវត្ត សាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ៗ

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១

ក្រឡាបញ្ជី

[redacted]